ព្រះរាជក្រឹត្យ

នស/រកត/០៨១៣/៤៩២

ស្តីពី

លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ROYAUME DU CAMBODGE ★ LE MINISTÈRE DU PALAIS ROYAL ★

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះមានគោលបំណងបង្កើតក្របខ័ណ្ឌដោយឡែករបស់មន្ត្រីពន្ធនាគារស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ដើម្បីធានាសិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍ស្របច្បាប់របស់មន្ត្រីពន្ធនាគារ។

**មាត្រា ២.-**

ព្រះរាជក្រឹត្យនេះមានគោលដៅដូចតទៅ ៖

- កំណត់អំពីការអនុវត្តសិទ្ធិ និងភារកិច្ចរបស់មន្ត្រីពន្ធនាគារ
- កំណត់អំពីលក្ខខណ្ឌ និងលក្ខណសម្បត្តិនៃការជ្រើសរើស ការរៀបចំឋានានុក្រម ឋានន្តរសក្តិ និងមុខតំណែងរបស់មន្ត្រីពន្ធនាគារ
- កំណត់អំពីការដំឡើងថ្នាក់ ឋានន្តរសក្តិ ការដាក់ទណ្ឌកម្មខាងវិន័យ និងការចោទប្រកាន់តាមផ្លូវតុលាការដល់មន្ត្រីពន្ធនាគារ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីពន្ធនាគារ ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ។

## ជំពូកទី២
## សិទ្ធិ កាតព្វកិច្ច និងភារកិច្ចរបស់មន្ត្រីពន្ធនាគារ

**មាត្រា ៤.-**

មន្ត្រីពន្ធនាគារត្រូវមានឧត្តមគតិស្នេហាជាតិខ្ពស់ មានភក្តីភាពចំពោះព្រះមហាក្សត្រ ហើយត្រូវគោរពវិន័យ សីលធម៌វិជ្ជាជីវៈនិងមានស្មារតីអង់អាចក្លាហាន ហ៊ានពុះពារលះបង់ ដើម្បីសម្រេចភារកិច្ចនៅគ្រប់កាលៈទេសៈ។

**មាត្រា ៥.-**

មន្ត្រីពន្ធនាគារមានសិទ្ធិ សេរីភាព និងកាតព្វកិច្ចដូចប្រជាពលរដ្ឋដទៃទៀតដែរ។ ការប្រើសិទ្ធិនិងសេរីភាព ត្រូវស្របតាមបទប្បញ្ញត្តិក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ បទបញ្ជារបស់ក្រសួងមហាផ្ទៃ និងច្បាប់នានាជាធរមាន។

**មាត្រា ៦.-**

មន្ត្រីពន្ធនាគារមានសិទ្ធិជ្រើសរើសជំនឿសាសនាដើម្បីគោរពប្រតិបត្តិ។ មន្ត្រីពន្ធនាគារមានសិទ្ធិចូលរួមក្នុងគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត ប៉ុន្តែមិនអាចសម្តែងជាសាធារណៈក្នុងពេលបំពេញភារកិច្ចតាមតួនាទីបានឡើយ។

**មាត្រា ៧.-**

មន្ត្រីពន្ធនាគារមានសិទ្ធិប្រមូលផ្តុំគ្នាបង្កើតជាសមាគមវិជ្ជាជីវៈ ឬចូលរួមជាសមាជិកសមាគមវិជ្ជាជីវៈស្របច្បាប់ណាមួយ។

**មាត្រា ៨.-**

មន្ត្រីពន្ធនាគារមានសិទ្ធិប្រើប្រាស់អាវុធនិងឧបករណ៍បច្ចេកទេស ដើម្បីធានាសន្តិសុខ សុវត្ថិភាពក្នុងនិងក្រៅបរិវេណមណ្ឌលអប់រំកែប្រែ ឬពន្ធនាគាររាជធានី ខេត្ត តាមគោលការណ៍កំណត់ ។

**មាត្រា ៩.-**

មន្ត្រីពន្ធនាគារមានសិទ្ធិសុំច្បាប់ឈប់គ្រប់ប្រភេទតាមការកំណត់របស់រាជរដ្ឋាភិបាល។ ក្នុងករណីចាំបាច់មន្ត្រីពន្ធនាគារដែលកំពុងឈប់សម្រាកអាចត្រូវកោះហៅឱ្យចូលខ្លួនមកវិញបាន។

មន្ត្រីពន្ធនាគារមានសិទ្ធិសុំមើលឯកសារផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងខ្លួនក្រោយពេលដែលការទទួលទណ្ឌកម្មខាងវិន័យ ឬត្រូវផ្លាស់ប្តូរដោយបង្ខំ។ សិទ្ធិដដែលនេះត្រូវបានអនុញ្ញាតឱ្យដល់មន្ត្រីពន្ធនាគារណាយឺតយូរមិនបានឡើងឋានន្តរសក្តិតាមវេនអតីតភាព។

ក្នុងករណីពិនិត្យឃើញឯកសារសំណុំរឿងនោះមិនប្រក្រតី ឬមិនត្រឹមត្រូវ មន្ត្រីពន្ធនាគារមាន :

- សិទ្ធិសំអាងសាក្សី
- សិទ្ធិជ្រើសរើសតំណាងការពារខ្លួន
- សិទ្ធិពន្យល់ដោះសារជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

**មាត្រា ១១.-**

មន្ត្រីពន្ធនាគារត្រូវមានអព្យាក្រឹតភាពក្នុងតួនាទី ឬការងាររបស់ខ្លួន។ ហាមការប្រើប្រាស់តួនាទី ឬការងារនិងការប្រើប្រាស់មធ្យោបាយ សម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនិងផលប្រយោជន៍បុគ្គល ឬអង្គការនយោបាយណាមួយ។

**មាត្រា ១២.-**

មន្ត្រីពន្ធនាគារមានកាតព្វកិច្ចរក្សាការសម្ងាត់របស់ជាតិ និងរបស់អង្គភាព។ ការផ្តល់ព័ត៌មានលិខិតស្នាម ឬឯកសារផ្ទៃក្នុងរបស់អង្គភាពដោយគ្មានការអនុញ្ញាតត្រូវហាមឃាត់។

**មាត្រា ១៣.-**

ការផ្សព្វផ្សាយក្នុងបរិវេណអង្គភាព ទោះបីជាតាមរូបភាពណាក៏ដោយដែលនាំឱ្យខូចទឹកចិត្តឬវិន័យត្រូវហាមឃាត់។ រាល់ការបកស្រាយជាសាធារណៈ ការសរសេរ ឬការធ្វើសន្និសីទសារព័ត៌មានពាក់ព័ន្ធនឹងអង្គភាពណាមួយត្រូវមានការអនុញ្ញាតពីប្រធានអង្គភាពនោះ។

**មាត្រា ១៤.-**

មន្ត្រីពន្ធនាគារត្រូវបំពេញភារកិច្ចតាមការចាត់តាំងនៅគ្រប់កាលៈទេសៈ គ្រប់ពេលវេលានិងគ្រប់ទីកន្លែង។ ប្រសិនបើភារកិច្ចនោះជួបឧបសគ្គនិងការលំបាកដែលចាំបាច់ត្រូវការឧបត្ថម្ភ ឬជំនួយ ថ្នាក់ដែលមានសមត្ថកិច្ចត្រូវតែបានផ្តល់ទៅតាមលក្ខណៈជាក់ស្តែង។ ទន្ទឹមនេះមន្ត្រីពន្ធនាគារដែលទទួលភារកិច្ចនោះក៏មានសិទ្ធិសុំជំនួយអន្តរាគមន៍ពីអង្គភាពដទៃដែលនៅជិតបំផុត។

**មាត្រា ១៥.-**

មន្ត្រីពន្ធនាគារអាចនឹងត្រូវបានផ្លាស់ប្តូរទីកន្លែង ភារកិច្ច ទៅតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ។ មន្ត្រីពន្ធនាគារមានសិទ្ធិសុំផ្លាស់ប្តូរទីកន្លែងធ្វើការទៅតាមប្តី ឬតាមប្រពន្ធបាន។

**មាត្រា ១៦.-**

មន្ត្រីពន្ធនាគារត្រូវបានហាមឃាត់ជាដាច់ខាតនូវប្រការដូចខាងក្រោម :

១- យកម៉ោងបំពេញភារកិច្ចទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត

២- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួន ទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែងបំពានសិទ្ធិពលរដ្ឋ ឬជនជាប់ឃុំ

៣- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីពន្ធនាគារ

៤- ចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល

៥- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងស្ថាប័ន ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ។



មន្ត្រីពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ នីតិវិធី និងក្រមសីលធម៌របស់មន្ត្រីពន្ធនាគារដែលមានជាធរមាន។ នៅពេលបំពេញបេសកកម្មការងារមានជួបគ្រោះថ្នាក់ ឬប៉ះពាល់ខាងផ្លូវច្បាប់ដោយអចេតនា រដ្ឋត្រូវគាំពារទាំងខាងមធ្យោបាយ សម្ភារ និងផ្លូវច្បាប់។

**មាត្រា ១៨.-**

មន្ត្រីពន្ធនាគារត្រូវបានទទួលពិន្ទុជារៀងរាល់ឆ្នាំសម្រាប់ពិនិត្យការដំឡើងថ្នាក់ ឋានន្តរសក្តិ។ ប្រធានអង្គភាពជាអ្នកវាយតម្លៃដាក់ពិន្ទុ និងផ្តល់មូលវិចារណ៍។

**មាត្រា ១៩.-**

មន្ត្រី ឬអង្គភាពពន្ធនាគារណាដែលមានស្នាដៃ ត្រូវបានទទួលការលើកទឹកចិត្ត ការសរសើរនិងជូនរង្វាន់តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការជ្រើសរើសមន្ត្រី

**មាត្រា ២០.-**

ការជ្រើសរើសមន្ត្រីឱ្យចូលធ្វើការក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវធ្វើតាមរយៈការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ឬក្នុងចំណោមមន្ត្រីរាជការដែលមានក្របខ័ណ្ឌស្រាប់។

លក្ខណសម្បត្តិជ្រើសរើសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ២១.-**

ការប្រឡងប្រជែងចូលឋានន្តរសក្តិអគ្គានុរក្សថ្នាក់លេខ៣ ត្រូវបានកំណត់ដូចខាងក្រោម :

១- បេក្ខជនជានិស្សិតទាំងពីរភេទ ត្រូវមានសញ្ញាប័ត្រយ៉ាងទាបសញ្ញាប័ត្របរិញ្ញាប័ត្រឬមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្របរិញ្ញាប័ត្រនិងត្រូវមានអាយុយ៉ាងច្រើន ៣០ (សាមសិប)ឆ្នាំគិតដល់ថ្ងៃប្រឡង។

២- បេក្ខជនជាមន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ដែលមានឋានន្តរសក្តិចាប់ពីអគ្គានុរក្សថ្នាក់លេខ៣ឡើងទៅនិងមានអតីតភាពយ៉ាងតិច០៣(បី)ឆ្នាំ ក្នុងឋានន្តរសក្តិអគ្គានុរក្សថ្នាក់លេខ៣ ឬជាមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារដែលមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្របរិញ្ញាប័ត្រ ហើយមានអតីតភាពការងារយ៉ាងតិច ០៦ (ប្រាំមួយ)ឆ្នាំ និងមានអាយុយ៉ាងច្រើនបំផុត៤០(សែសិប)ឆ្នាំ គិតដល់ថ្ងៃប្រឡង។

**មាត្រា ២២.-**

ការប្រឡងប្រជែងចូលឋានន្តរសក្តិអនុរក្សថ្នាក់លេខ៣ ត្រូវធ្វើចំពោះបេក្ខជនជាសិស្ស និស្សិតទាំងពីរភេទដែលមានសញ្ញាប័ត្រយ៉ាងទាបសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឬមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងត្រូវមានអាយុយ៉ាងច្រើន ២៥(ម្ភៃប្រាំ)ឆ្នាំ គិតដល់ថ្ងៃប្រឡង។

**មាត្រា ២៣.-**

ចំនួនក្របខ័ណ្ឌមន្ត្រីពន្ធនាគារដែលធ្វើការជ្រើសរើស ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ២៤.-**

បេក្ខជនទាំងពីរភេទដែលបានប្រឡងប្រជែងជាប់ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានទទួលការបណ្តុះបណ្តាលជាដំបូងដោយក្រសួងមហាផ្ទៃ។ រយៈពេលបណ្តុះបណ្តាលនេះនឹងចាត់ទុកជារយៈពេលនៃកម្មសិក្សារបស់សិស្សមន្ត្រីទាំងនោះ។

មន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិតត្រូវឆ្លងកាត់កម្មសិក្សាសាកល្បងរយៈពេល១២(ដប់ពីរ)ខែ។ ប្រសិនបើបេក្ខជនជាមន្ត្រីរាជការដែលបានប្រឡងជាប់ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្នុងឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ៣ ដូចមានចែងក្នុងមាត្រា២១ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ។

**មាត្រា ២៥.-**

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងសិស្សមន្ត្រីពន្ធនាគារទាំងនោះ ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌដូចខាងក្រោម :

- សិស្សវរអគ្គានុរក្សពន្ធនាគារត្រូវបានបញ្ចូលក្របខ័ណ្ឌ និងតែងតាំងឋានន្តរសក្តិថ្នាក់វរអគ្គានុរក្សថ្នាក់លេខ៣ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សិស្សអគ្គានុរក្សពន្ធនាគារត្រូវបានបញ្ចូលក្របខ័ណ្ឌ និងតែងតាំងឋានន្តរសក្តិថ្នាក់អនុរក្សថ្នាក់លេខ៣ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ចំពោះសិស្សអគ្គានុរក្សពន្ធនាគារដែលមានសញ្ញាប័ត្របរិញ្ញាប័ត្ររងឬមានសញ្ញាប័ត្រសមមូលជាមួយនឹងសញ្ញាប័ត្របរិញ្ញាប័ត្ររងត្រូវបានតែងតាំងឋានន្តរសក្តិថ្នាក់អនុរក្សថ្នាក់លេខ១ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ២៦.-**

ក្នុងករណីក្រសួងមហាផ្ទៃពុំមានលទ្ធភាពធ្វើការបណ្តុះបណ្តាលដំបូង ក្រសួងមហាផ្ទៃអាចចាត់បញ្ជូនសិស្ស និស្សិតដែលបានប្រឡងប្រជែងជាប់ជាស្ថាពរក្នុងក្របខ័ណ្ឌ និងឋានន្តរសក្តិនីមួយៗឱ្យចូលបំពេញការងារនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្តបាន។ ក្រោយពីបំពេញការងារបានរយៈពេល១២(ដប់ពីរ)ខែ សិស្ស និស្សិតទាំងនោះត្រូវបានតាំងស៊ប់និងតែងតាំងឋានន្តរសក្តិដូចបានបណ្តុះបណ្តាលដែរ។

## ជំពូកទី៤
## លំដាប់ឋានន្តរសក្តិ និងមុខតំណែង

**មាត្រា ២៧.-**

ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារមាន ៣(បី) គឺ :

១- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ

២- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ

៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ

**មាត្រា ២៨.-**

លំដាប់ថ្នាក់ ឋានន្តរសក្តិមន្ត្រីពន្ធនាគារ មាន :

១- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ មាន ៣ថ្នាក់ :
- ឧត្តមអគ្គានុរក្សថ្នាក់លេខ ១
- ឧត្តមអគ្គានុរក្សថ្នាក់លេខ ២
- ឧត្តមអគ្គានុរក្សថ្នាក់លេខ ៣

២- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ មាន ៣ថ្នាក់ :
- វរអគ្គានុរក្សថ្នាក់លេខ ១
- វរអគ្គានុរក្សថ្នាក់លេខ ២
- វរអគ្គានុរក្សថ្នាក់លេខ ៣

៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ មាន ៧ថ្នាក់ :

- អគ្គានុរក្សថ្នាក់លេខ ១
- អគ្គានុរក្សថ្នាក់លេខ ២
- អគ្គានុរក្សថ្នាក់លេខ ៣
- អគ្គានុរក្សថ្នាក់លេខ ៤
- អនុរក្សថ្នាក់លេខ ១
- អនុរក្សថ្នាក់លេខ ២
- អនុរក្សថ្នាក់លេខ ៣

**មាត្រា ២៩.-**

ឋានន្តរសក្តិមន្ត្រីពន្ធនាគារដូចមានចែងក្នុងមាត្រា២៨ខាងលើនេះ ត្រូវមានឋានន្តរសក្តិសមមូលជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិនៃក្រសួងមហាផ្ទៃ។

ការកំណត់អំពីឋានន្តរសក្តិសមមូលនេះ ត្រូវធ្វើដោយអនុក្រឹត្យ។

**មាត្រា ៣០.-**

ឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិមន្ត្រីពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៣១.-**

ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារមានឧបនិស្ស័យកាន់មុខតំណែងដូចខាងក្រោម :

- ឧត្តមអគ្គានុរក្សថ្នាក់លេខ១ ជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ
- ឧត្តមអគ្គានុរក្សថ្នាក់លេខ២ ជាអគ្គនាយករង ឬជាប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានពន្ធនាគារ
- ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ ជាអនុប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ឬជាប្រធានមណ្ឌលអប់រំកែប្រែឬជាប្រធានពន្ធនាគាររាជធានី ខេត្ត។

**មាត្រា ៣២.-**

ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារមានឧបនិស្ស័យកាន់មុខតំណែងដូចខាងក្រោម :

- វរអគ្គានុរក្សថ្នាក់លេខ១ ជាប្រធានការិយាល័យថ្នាក់កណ្តាល ឬជាអនុប្រធានមណ្ឌលអប់រំកែប្រែ ឬជាអនុប្រធានពន្ធនាគាររាជធានី ខេត្ត
- វរអគ្គានុរក្សថ្នាក់លេខ២ ជាអនុប្រធានការិយាល័យថ្នាក់កណ្តាល ឬជាប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត
- វរអគ្គានុរក្សថ្នាក់លេខ៣ ជាប្រធានផ្នែកថ្នាក់កណ្តាល ឬជាអនុប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត។

**មាត្រា ៣៣.-**

ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារមានឧបនិស្ស័យកាន់មុខតំណែងដូចខាងក្រោម :

- អគ្គានុរក្សថ្នាក់លេខ១ ជាអនុប្រធានផ្នែកថ្នាក់កណ្តាល ឬជាប្រធានផ្នែកនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត
- អគ្គានុរក្សថ្នាក់លេខ២ ជានាយត្រួតថ្នាក់កណ្តាល ឬជាអនុប្រធានផ្នែកនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត
- អគ្គានុរក្សថ្នាក់លេខ៣ ជានាយត្រួតរងថ្នាក់កណ្តាល ឬជាប្រធានក្រុមនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ការដំឡើងថ្នាក់ ឋានន្តរសក្តិ

**មាត្រា ៣៤.-**

ការដំឡើងថ្នាក់ ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារត្រូវគិតអំពីលក្ខណសម្បត្តិ និងអតីតភាពការងារដែលបានបំពេញក្នុងរយៈកាលកន្លងមក។

**មាត្រា ៣៥.-**

លក្ខណសម្បត្តិសម្រាប់ពិនិត្យក្នុងការស្នើដំឡើងថ្នាក់ ឋានន្តរសក្តិត្រូវផ្អែកលើ :

១- ការគោរពវិន័យ ការចាត់តាំងនិងការអនុវត្តបទបញ្ជា និងនីតិវិធីពន្ធនាគារ

២- កិរិយាមារយាទ សីលធម៌ ស្មារតីសាមគ្គីសហប្រតិបត្តិការក្នុងការបំពេញភារកិច្ច

៣- សមត្ថភាពបំពេញការងារវិជ្ជាជីវៈ បង្កើនចំណេះដឹងទូទៅ មុខជំនាញបច្ចេកទេស ភាសាបរទេស។

**មាត្រា ៣៦.-**

ការដំឡើងថ្នាក់ ឋានន្តរសក្តិរបស់មន្ត្រីពន្ធនាគារក្នុងថ្នាក់ ឋានន្តរសក្តិនីមួយៗត្រូវអនុវត្តតាមវេនជ្រើសរើសនិងតាមរយៈពេលកំណត់ដូចមានចែងខាងក្រោម :

### ១- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ

| ឋានន្តរសក្តិ | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិ ដើម្បីអាចដំឡើងបានមួយថ្នាក់ |
|---|---|
| ឧត្តមអគ្គានុរក្សថ្នាក់លេខ១ | |
| ឧត្តមអគ្គានុរក្សថ្នាក់លេខ២ | ០៥ ឆ្នាំ |
| ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ | ០៥ ឆ្នាំ |

### ២- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារ

| ឋានន្តរសក្តិ | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិ ដើម្បីអាចដំឡើងបានមួយថ្នាក់ |
|---|---|
| វរអគ្គានុរក្សថ្នាក់លេខ១ | ០៦ ឆ្នាំ |
| វរអគ្គានុរក្សថ្នាក់លេខ២ | ០៥ ឆ្នាំ |
| វរអគ្គានុរក្សថ្នាក់លេខ៣ | ០៥ ឆ្នាំ |

- វរអគ្គានុរក្សថ្នាក់លេខ១ ដែលមានអតីតភាព០៦(ប្រាំមួយ)ឆ្នាំឡើង អាចត្រូវបានស្នើសុំតែងតាំងនិងសុំដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ដោយយោងទៅតាមមុខតំណែងទំនេរ ឬតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

### ៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ

| ឋានន្តរសក្តិ | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិ ដើម្បីអាចដំឡើងបានមួយថ្នាក់ |
|---|---|
| អគ្គានុរក្សថ្នាក់លេខ១ | ០៣ ឆ្នាំ |
| អគ្គានុរក្សថ្នាក់លេខ២ | ០៣ ឆ្នាំ |
| អគ្គានុរក្សថ្នាក់លេខ៣ | ០៣ ឆ្នាំ |
| អគ្គានុរក្សថ្នាក់លេខ៤ | ០៣ ឆ្នាំ |
| អនុរក្សថ្នាក់លេខ១ | ០២ ឆ្នាំ |
| អនុរក្សថ្នាក់លេខ២ | ០២ ឆ្នាំ |
| អនុរក្សថ្នាក់លេខ៣ | ០១ ឆ្នាំ |

បណ្ដាលបន្ថែមនិងដំឡើងឋានន្តរស័ក្តិវរអគ្គានុរក្សថ្នាក់លេខ៣ ដោយយោងទៅតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ។

**មាត្រា ៣៧.-**

ចំពោះមន្ត្រីពន្ធនាគារដែលបានទទួលមរណភាពត្រូវបានដំឡើងថ្នាក់ ឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ។

**មាត្រា ៣៨.-**

ការដំឡើងថ្នាក់ ឋានន្តរស័ក្តិត្រូវប្រព្រឹត្តទៅតាមលំដាប់ថ្នាក់មួយថ្នាក់ម្ដងៗ ហើយពុំអាចមានការតែងតាំងជាឋានន្តរស័ក្តិកិត្តិយសឡើយ។ ក្នុងករណីមន្ត្រីពន្ធនាគារណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានដំឡើងថ្នាក់ ឋានន្តរស័ក្តិមួយថ្នាក់ដោយពុំគិតពីលក្ខខណ្ឌអតីតភាពឡើយ។

**មាត្រា ៣៩.-**

ការដំឡើងថ្នាក់ ឋានន្តរស័ក្តិរបស់មន្ត្រីពន្ធនាគារត្រូវប្រព្រឹត្តទៅតាមលំដាប់នៃបញ្ជីអតីតភាព។ ក្នុងករណីអ្នកមានអតីតភាពគ្រប់ ហើយមិនបានជាប់ឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ មន្ត្រីពន្ធនាគារនោះត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេតាមលេខរៀងក្នុងតារាងដំឡើងថ្នាក់ ឋានន្តរស័ក្តិឆ្នាំបន្ទាប់ លើកលែងតែបុគ្គលនោះបានប្រព្រឹត្តអំពើល្មើសនឹងវិន័យ នីតិវិធី លក្ខន្តិកៈ ឬច្បាប់របស់រដ្ឋ។

**មាត្រា ៤០.-**

ការតែងតាំងនិងដំឡើងថ្នាក់ ឋានន្តរស័ក្តិ ត្រូវសម្រេចដោយ :

- ព្រះរាជក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរស័ក្តិឧត្តមអគ្គានុរក្សពន្ធនាគារ
- អនុក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរស័ក្តិវរអគ្គានុរក្សថ្នាក់លេខ១
- ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះមន្ត្រីពន្ធនាគារចាប់ពីឋានន្តរស័ក្តិវរអគ្គានុរក្សថ្នាក់លេខ២ចុះ។

## ជំពូកទី៦
## បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ

**មាត្រា ៤១.-**

មន្ត្រីពន្ធនាគារមានសិទ្ធិទទួលបៀវត្សទៅតាមឋានន្តរស័ក្តិ។

មន្ត្រីពន្ធនាគារអាចទទួលប្រាក់បំណាច់ផ្សេងៗតាមប្រភេទមុខងារ ឬតំណែងដែលខ្លួនបំពេញ ប្រាក់ឧបត្ថម្ភតំបន់ ប្រាក់ឧបត្ថម្ភការងារងាយប៉ះពាល់ដល់សុខភាព ប្រាក់វិភាជន៍គ្រួសារ និងប្រាក់ឧបត្ថម្ភផ្សេងទៀត។

បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីពន្ធនាគារត្រូវកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

**មាត្រា ៤២.-**

មន្ត្រីពន្ធនាគារជាស្ត្រី ត្រូវបានទទួលប្រាក់ឧបត្ថម្ភលំហែមាតុភាពតាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី៧
## ការចូលនិវត្តន៍

**មាត្រា ៤៣.-**

មន្ត្រីពន្ធនាគារដែលបានបម្រើការងារក្នុងក្របខណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានដាក់ឱ្យចូលនិវត្តន៍ដូចខាង :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះទេរោជវាំង

ពន្ធនាគារ

ខ-នៅពេលគ្រប់អាយុ ៥៨ឆ្នាំ ចំពោះមន្ត្រីពន្ធនាគារស្ថិតក្នុងឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារ

គ-នៅពេលគ្រប់អាយុ ៦០ឆ្នាំ ចំពោះមន្ត្រីពន្ធនាគារ ស្ថិតក្នុងឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ។

ការដាក់ឱ្យចូលនិវត្តន៍ត្រូវសម្រេចដោយ :

- ព្រះរាជក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារមានឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ
- អនុក្រឹត្យ ចំពោះមន្ត្រីពន្ធនាគារមានឋានន្តរសក្តិអគ្គានុរក្សថ្នាក់លេខ១
- ប្រកាសរបស់ក្រសួងមហាផ្ទៃ ចំពោះមន្ត្រីពន្ធនាគារចាប់ពីឋានន្តរសក្តិអគ្គានុរក្សថ្នាក់លេខ២ចុះ។

មន្ត្រីពន្ធនាគារជាស្ត្រី ត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១២/៨៤៨ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលជាស្ត្រី។

## ជំពូកទី៨

## ទណ្ឌកម្ម

**មាត្រា ៤៤.-**

មន្ត្រីពន្ធនាគារដែលមានកំហុសត្រូវទទួលទណ្ឌកម្មខាងវិន័យ ដូចខាងក្រោម ៖

១-ទណ្ឌកម្មដែលកំណត់ដោយក្រមសីលធម៌ និងបទវិន័យ ឬដោយនីតិវិធីពន្ធនាគារ

២-ទណ្ឌកម្មដែលកំណត់ដោយមាត្រា៤៦នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៤៥.-**

ការដាក់ទណ្ឌកម្មតាមបទវិន័យ ឬនីតិវិធី ឬលក្ខន្តិកៈដោយឡែកនេះ ត្រូវសុំយោបល់ពីក្រុមប្រឹក្សាវិន័យជាមុន។

**មាត្រា ៤៦.-**

ក្រោយទទួលបានយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម្រេចដាក់ទណ្ឌកម្ម ឬស្នើសុំដាក់ទណ្ឌកម្មខាងវិន័យ ដែលរួមមានដូចខាងក្រោម :

ក- ស្តីបន្ទោស

ខ- ការផ្លាស់ការកិច្ចដោយបង្ខំ

គ- ការលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឋានន្តរសក្តិ

ឃ-ការដកមុខតំណែងដោយឱ្យនៅក្នុងស្ថានភាពអសកម្ម

ង- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនឱ្យលើសពី០១(មួយ)ឆ្នាំ

ច- ការបន្ថយថ្នាក់ ឋានន្តរសក្តិមួយថ្នាក់ឬច្រើនថ្នាក់

ឆ- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់

ជ- ការលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីពន្ធនាគារ។

**មាត្រា ៤៧.-**

ការដកមុខតំណែងដោយដាក់ក្នុងស្ថានភាពអសកម្មត្រូវអនុវត្តចំពោះតែមន្ត្រីពន្ធនាគារណាដែលមិនត្រូវចូលនិវត្តន៍ភ្លាមៗ។ ការដកមុខតំណែងមិនអាចមានរយៈពេលលើសពី២(ពីរ)ឆ្នាំ។

នៅពេលផុតកំណត់នៃរយៈពេលដែលស្ថិតនៅក្នុងស្ថានភាពអសកម្ម មន្ត្រីពន្ធនាគារនោះត្រូវដាក់ឱ្យនៅក្នុងស្ថានភាពសកម្មវិញ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជាឡើងថ្នាក់ ឋានន្តរសក្តិទេ។

**មាត្រា ៤៨.-**

មន្ត្រីពន្ធនាគារដែលត្រូវបានបន្ថយថ្នាក់ ឋានន្តរសក្តិត្រូវបញ្ចូលទៅក្នុងតារាងដំឡើងថ្នាក់ ឋានន្តរសក្តិថ្មី ចាប់គិតពីថ្ងៃដែលមានការសម្រេចជាផ្លូវការ។

## ជំពូកទី៩

## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ៤៩.-**

ក្នុងករណីដែលមន្ត្រីពន្ធនាគារណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានអាជ្ញាធរតុលាការធ្វើការចោទប្រកាន់ត្រូវជូនដំណឹងអំពីការចោទប្រកាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេល ៧២(ចិតសិបពីរ)ម៉ោង យ៉ាងយូរ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនបណ្តោះអាសន្នលើមន្ត្រីពន្ធនាគារណាមួយនោះ អាជ្ញាធរតុលាការត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៥០.-**

មន្ត្រីពន្ធនាគារណាដែលកំពុងជាប់ការចោទប្រកាន់ពីអាជ្ញាធរតុលាការ អាចត្រូវបានផ្អាកពីមុខងារសិនក្នុងករណីចាំបាច់។

ក្នុងករណីអាជ្ញាធរតុលាការសម្រេចលើកលែងការចោទប្រកាន់ជាស្ថាពរ មន្ត្រីពន្ធនាគារនោះត្រូវបានទទួលឱ្យចូលធ្វើការវិញភ្លាម ដោយគិតអតីតភាពសម្រាប់ការឡើងថ្នាក់ ឋានន្តរសក្តិ និងអតីតភាពចូលនិវត្តន៍ ព្រមទាំងទទួលបៀវត្សប្រតិសកម្មផង។

**មាត្រា ៥១.-**

មន្ត្រីពន្ធនាគារណាដែលត្រូវបានផ្តន្ទាទោសដោយអាជ្ញាធរតុលាការ ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ដោយគិតពីថ្ងៃចេញសាលក្រមស្ថាពរ។

មន្ត្រីពន្ធនាគារដែលបានតវ៉ាសុំឧទ្ធរណ៍ត្រូវដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

**មាត្រា ៥២.-**

ក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវបានកសាងចេញពីសមាហរណកម្មនៃក្របខ័ណ្ឌមន្ត្រីរាជការទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែងនិងមុខងារពិតប្រាកដនៅក្នុងអគ្គនាយកដ្ឋានពន្ធនាគារ ឬក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឬក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ។

ការធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីខាងលើនេះ ទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស។

**មាត្រា ៥៣.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធនាគារដែលបានអនុវត្តកន្លងមកនៅមានសុពលភាពរហូតដរាបណាគ្មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមខ្លឹមសារនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា ៥៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥៥.-

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យមានប្រសិទ្ធភាព។

មាត្រា ៥៦.-

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចសល. ១៣០៤.៩០៦

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

សូមចុះហត្ថលេខា។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

លេខ: ៨៨៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

**រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៣**

**អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**